**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**លេខ៖ បព ៧២/២០២៦ កបទ.សអ** សេចក្តីប្រកាសព័ត៌មាន

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ជួបជាមួយ តំណាងប្រធានាធិបតីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ទទួលបន្ទុកកិច្ចការពិសេស

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារប្រកបដោយផ្លែផ្កាជាមួយ **ឯកឧត្តម អែលឈីន អាមៀរបាយ៉ូវ** តំណាងប្រធានាធិបតីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ទទួលបន្ទុកកិច្ចការពិសេស ក្នុងអំឡុងពេលនៃការបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី០៩-១៤ ខែឧសភា ឆ្នាំ២០២៦។

ក្នុងឱកាសនៃជំនួបនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចការងាររបស់ **ឯកឧត្តម អែលឈីន អាមៀរបាយ៉ូវ** មកកាន់កម្ពុជា និងបានសម្តែងនូវការពេញចិត្តចំពោះការបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងអាស៊ែបៃហ្សង់ ផ្អែកលើការគោរព និងការយោគយល់គ្នាទៅវិញទៅមក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកពី លទ្ធផលជាផ្លែផ្កានៃទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីកម្ពុជា កាលពីឆ្នាំ២០១៤ នៅសាធារណរដ្ឋអាស៊ែបៃហ្សង់ និងបានលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់បន្ថែមទៀត ដើម្បីធ្វើឱ្យទំនាក់ទំនងទ្វេភាគីកាន់តែស៊ីជម្រៅ និងបង្កើនកិច្ចសហការសម្រាប់ផលប្រយោជន៍ ទៅវិញទៅមកនៃប្រទេសទាំងពីរ។

ជាការឆ្លើយតប **ឯកឧត្តមអាមៀរបាយ៉ូវ** បានលើកឡើងថា អាស៊ែបៃហ្សង់ចាត់ទុកកម្ពុជាជាដៃគូដ៏សំខាន់ និងបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពល្អនៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីររួមទាំងការផ្សារភ្ជាប់ទំនាក់ទំនងរវាងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។ **ឯកឧត្តម**បានបញ្ជាក់អំពីចំណាប់អារម្មណ៍របស់អាស៊ែបៃហ្សង់ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាលើវិស័យដែលមានសក្តានុពលជាច្រើន ក៏ដូចជាការលើកកម្ពស់ទំនាក់ទំនងវិស័យឯកជន និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមអាមៀរបាយ៉ូវ** ក៏បានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាក្តីកង្វល់រួម ដោយបានគូសបញ្ជាក់អំពីភាពចាំបាច់នៃការគោរពច្បាប់អន្តរជាតិ និងគាំទ្រដំណោះស្រាយជម្លោះដោយសន្តិវិធីតាមផ្លូវការទូត និងច្បាប់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរជាថ្មីម្តងទៀតចំពោះសេចក្តីថ្លែងការណ៍រួមស្តីពីសន្តិភាពជាប្រវត្តិសាស្ត្រ ដែលចុះហត្ថលេខាដោយអាស៊ែបៃហ្សង់ និងអាមេនី កាលពីឆ្នាំទៅ និងបានជម្រាបជូនភ្ញៀវអំពីបច្ចុប្បន្នភាពនៃស្ថានការណ៍ព្រំដែនកម្ពុជា-ថៃផងដែរ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ក្នុងឱកាសនៃទស្សនកិច្ចនេះ **ឯកឧត្តម អែលឈីន អាមៀរបាយ៉ូវ** បានជួបសម្តែងការគួរសមជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី និងជាប្រធានព្រឹទ្ធសភា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ **ឯកឧត្តម អាមៀរបាយ៉ូវ** ក៏បានជួបពិភាក្សាជាមួយប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងនាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC)។ **ឯកឧត្តមតំណាងប្រធានាធិបតីអាស៊ែបៃហ្សង់** ក៏បានផ្តល់បទសម្ភាសន៍ជាមួយសារព័ត៌មានក្នុងស្រុកអំពីទំនាក់ទំនងទ្វេភាគីកម្ពុជា-អាស៊ែបៃហ្សង់ផងដែរ៕

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៦